ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៩

ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩

សាលដីកា

លេខ ៨១ IV

ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

## សាលដីកា

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជាសាធារណៈ ពិភាក្សាដេញដោល ស្តាប់សេចក្តីសន្និដ្ឋានភាគីពាក់ព័ន្ធ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ដោយអង្គជំនុំជម្រះដែលមានសមាសភាពចៅក្រមដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.លោក [redacted] ជាចៅក្រម

៣.លោក [redacted] ជាចៅក្រម

៤.លោក [redacted] ជាចៅក្រមរបាយការណ៍

៥.លោក [redacted] ជាចៅក្រម

### ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted]

### តំណាងមហាអយ្យការ

-ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៦៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាលីន ចំពោះសាលដីកាលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

១.ជនត្រូវចោទឈ្មោះ [redacted] ខួន ភេទប្រុស កើតឆ្នាំ ១៩៦៨ សញ្ជាតិខ្មែរ កំរិតវប្បធម៌អនុបណ្ឌិត មុខរបរជាមន្ត្រីរាជការ ទីកន្លែងកំណើតនៅសង្កាត់លេខ [redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅភូមិ៣ [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន។

(ក្រៅឃុំ)



Scanned with CamScanner

២.ជនត្រូវចោទឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ កំរិតវប្បធម៌ថ្នាក់ទី ៧ មុខរបរនៅផ្ទះ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាលីន ភេទស្រី អាយុ ៤០ ឆ្នាំ មុខរបរស្ត្រីមេផ្ទះ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រះសីហនុ។ (អ្នកប្តឹងសាទុក្ខ)

**អំពីអង្គហេតុ**

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ដាលីន បានបញ្ជាក់ថា កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៧ ឈ្មោះ [redacted] ងួន និងប្រពន្ធឈ្មោះ [redacted] ធូ បានសាងសង់របងឥដ្ឋបិទតជាប់នឹងបង្គោលរបងផ្លូវចេញចូលផ្ទះ ត្រង់ខ្លោងទ្វាររបងផ្ទះចូលមកក្នុងដីរបស់ឈ្មោះ [redacted] ដាលីន អស់ប្រវែង ៣ ម៉ែត្រ ដូចមាននៅក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០-៣០៣-០៤៣០ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-បានឃើញដីកាដំណោះស្រាយលេខ ១៧៦១ តពរ/១៩ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-លើកលែងការចោទប្រកាន់លើ៖

១.ឈ្មោះ [redacted] ងួន ភេទប្រុស (មានសាវតាជាតិដូចខាងលើ)

២.ឈ្មោះ [redacted] ធូ ភេទស្រី (មានសាវតាជាតិដូចខាងលើ)

៣.បក្សពួក

ពីបទប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុអ្នកដទៃដោយសុចរិត ប្រព្រឹត្តនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល នោះឡើយ។ គប្បីតុលាការពិចារណា។



Scanned with CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តទៅនឹងដីកាដំណោះស្រាយលេខ ១៧៦១ តព/១៩ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តម្កល់ដីកាដំណោះស្រាយលេខ ១៧៦១ តព/១៩ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល។

៣.សាលដីកានេះ ប្រកាសជាអសាធារណៈ នៅថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣៦៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាលីន ប្តឹងសាទុក្ខមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណី ពុំបានប្តឹងឧទ្ធរណ៍ ដូចនេះដើមបណ្តឹងរដ្ឋប្បវេណីពុំអាចប្តឹងសាទុក្ខបានឡើយ គប្បីបដិសេធចោល។ ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៦៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាលីន ប្តឹងសាទុក្ខនឹងសាលដីកាលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ ដូច្នេះតុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញតិមាត្រា ៤១៧, ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ក្នុងរឿងក្តីនេះចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុបានចេញដីកាដំណោះស្រាយ លើកលែងការចោទប្រកាន់លើឈ្មោះ [redacted] ងួន និងឈ្មោះ [redacted] ធូ តាមដីកាលេខ ១៧៦១ តពរ/១៩ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ដូចខាងលើនេះទេ។ ប៉ុន្តែតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយលើកលែងការចោទប្រកាន់លើឈ្មោះ [redacted] ងួន និងឈ្មោះ [redacted] ធូ តាមដីកាលេខ ១៧៦១ តពរ/១៩ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តព្រះសីហនុ។ សភាស៊ើបសួរសាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ដោយតម្កល់ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ មហាអយ្យការមិនបានប្តឹងសាទុក្ខនឹងសាលដីកានេះទេ។ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តព្រះសីហនុ ហេតុដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីពុំមានគុណវុឌ្ឍិក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាលេខ ៧៤ ក្រIII"ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ សភាស៊ើបសួរសាលាឧទ្ធរណ៍បានឡើយ។ ហេតុដូច្នេះ តុលាការកំពូលគប្បីសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង ។

៣-យល់ឃើញថា សាលដីកាលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធចោលទាំងស្រុងនូវបណ្តឹងសាទុក្ខលេខ ៣៦៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាលីន ។



Scanned with CamScanner

២- តម្កល់សាលដីកាលេខ ៧៤ ក្រIII "ឃ" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាជំនុំជម្រះសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២០ និងប្រកាសចាសវនាការជាសាធារណៈនៅថ្ងៃសុក្រ ទី២៧ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner